**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២១ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា **នៅខេត្តប៉ៃលិន** ដែលមានសមាសភាពដូចខាងក្រោមៈ



www.pheakdeylaw.com

| | | |
|---|---|---|
| ១. ឯ.ឧ ប៉ាន សូរស័ក្តិ | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២. ឯ.ឧ អ៊ិក ប្រជា | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣. ឯ.ឧ សាវ សុខ | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៤. ឯ.ឧ ឈឹម សៅគី | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥. ឯ.ឧ កើត មៀច | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៦. ឯ.ឧ អៀង សុផល | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៧. ឯ.ឧ ឈឹម ឈន | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៨. ឯ.ឧ ជា សៃ | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៩. ឯ.ឧ ហាប់ អូម៉ាលី | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១០. ឯ.ឧ អ៊ិន វិធុរៈ | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |

| | |
|---|---|
| ១១. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១២. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៣. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៤. តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៥. តំណាងក្រសួងបរិស្ថាន | សមាជិក |
| ១៦. តំណាងក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៧. តំណាងក្រសួងព័ត៌មាន | សមាជិក |
| ១៨. តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| ១៩. តំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ២០. តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២១. តំណាងក្រសួងកិច្ចការនារី | សមាជិក |
| ២២. តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២៣. តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២៤. តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២៥. តំណាងក្រសួងធម្មការ និងសាសនា | សមាជិក |
| ២៦. តំណាងក្រសួងផែនការ | សមាជិក |
| ២៧. តំណាងក្រសួងមុខងារសាធារណៈ | សមាជិក |
| ២៨. តំណាងក្រសួងរ៉ែ និងថាមពល | សមាជិក |
| ២៩. តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |

**ប្រការ២.**_

អភិបាលនៃគណៈអភិបាលខេត្តត្រូវបានប្រគល់ភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារថ្នាក់ជាតិប្រចាំខេត្តរបស់ខ្លួន។

តួនាទី ភារកិច្ច របៀបរបបការងាររបស់ក្រុមការងារត្រូវកំណត់ដោយសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រធានក្រុមការងារមានសិទ្ធិសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ដើម្បីចាត់មន្ត្រីថ្នាក់អគ្គនាយក អគ្គនាយករង ឬមន្ត្រីថ្នាក់ប្រហាក់ប្រហែលឲ្យចូលរួមក្នុងក្រុមការងារនេះ។



www.pheakdeylaw.com

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័ន រដ្ឋបាលខេត្តប៉ៃលិន និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:

- *-ក្រសួងព្រះបរមរាជវាំង*
- *-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *-អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *-គ្រប់ក្រសួង ស្ថាប័ន*
- *-រដ្ឋបាលថ្នាក់ក្រោមជាតិ*
- *-រាជកិច្ច*
- *-ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com